ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកញ្ញា និងទិសដៅការងារខែតុលា ឆ្នាំ២០១៩

## • សេចក្តីផ្តើម

នៅក្នុងខែកញ្ញានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារតាមតួនាទី ភារកិច្ចយ៉ាងសកម្មលើមុខងារទាំងប្រាំ ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

### ១- មុខងារនីតិកម្ម

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| | - បានសហការរៀបចំជូនសមាជិកព្រឹទ្ធសភាថ្មី ចំនួន០៣រូប ចូលធ្វើសច្ចាប្រណិធាន<br>- បានថតចម្លងឯកសារចំនួន៥៣ច្បាប់ អស់ក្រដាសចំនួន១,៣៧៧សន្លឹក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន០១លើក ស្មើនឹង៥៥នាក់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន០៦លើក<br>- បានផ្តល់សេវារថយន្តសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចុះ |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

| | |
|---|---|
| | បំពេញបេសកកម្មនៅរាជធានីភ្នំពេញចំនួន ០៥លើក ស្មើនឹង០៥នាក់<br>- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់ ពីរាជរដ្ឋាភិបាល ហើយបានចាត់ចែងតាមនីតិវិធី<br>- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកាអម សេចក្តីសម្រេច និងលិខិតផ្សេងៗ ចំនួន១៨០ច្បាប់ ហើយបានចាត់ចែងតាមនីតិវិធី<br>- បានធ្វើឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ ចំនួន០៣ច្បាប់<br>- បានបញ្ចូលព្រះរាជក្រម ព្រះរាជក្រឹត្យ និងអនុក្រឹត្យ ចំនួន១២៤ប្រធានបទ ទៅក្នុងវេបសាយច្បាប់ (Laws.gov.kh)<br>- បានប្រចាំការថតសំឡេង ថតវីដេអូ និងរៀបចំ ប្រព័ន្ធសំឡេងចំនួន១៧លើក<br>- បានថត និងផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹង សេចក្តីប្រកាសព័ត៌មានចំនួន០៦លើក។ |

## ២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភាបាន៖<br>+ អញ្ជើញចុះជួបសំណេះសំណាលជាមួយ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុក ខណ្ឌ និង ថ្នាក់ដឹកនាំ និងមន្ត្រីនៃសាលាខេត្ត ព្រមទាំង តុលាការ និងអយ្យការអមតុលាការខេត្ត ដើម្បីឈ្វេងយល់ការអនុវត្តច្បាប់ និងបញ្ហា ប្រឈមនានា ក្នុងការអនុវត្តក្រមទាំង៤ និង ការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ នៅខេត្តកែវ ខេត្តកែប និងខេត្តកំពត<br>+ អញ្ជើញចុះជួបសំណេះសំណាល និង | - បានធ្វើលិខិតបេសកកម្ម ជូនសមាជិក សមាជិកា ព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភាចំនួន៣២នាក់ ស្មើនឹង០៨ច្បាប់<br>- បានថតចម្លងឯកសារចំនួន១៦ច្បាប់ អស់ក្រដាស ចំនួន៧៣២សន្លឹក<br>- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាព ការងាររបស់សមាជិក សមាជិកាព្រឹទ្ធសភា បំពេញការងារតាមវិស័យជាសមត្ថកិច្ចរបស់ គណៈកម្មការ នៅរាជធានីភ្នំពេញ និងនៅតាម បណ្តាខេត្ត ក្រុងចំនួន១០លើក។ |

| | |
|---|---|
| ពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្ត ប្រធានមន្ទីរ និងអង្គភាពពាក់ព័ន្ធ ដើម្បីសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការអភិវឌ្ឍមូលដ្ឋាន នៅខេត្តព្រះវិហារ<br>+ អញ្ជើញចុះសិក្សាឈ្វេងយល់អំពីការវិវត្តរីកចម្រើន បញ្ហាប្រឈមរបស់ខេត្តពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដោយផ្តោតលើបញ្ហាសុខភាពសាធារណៈ ការអនុវត្តច្បាប់អន្តោប្រវេសន៍ ការផ្សព្វផ្សាយព័ត៌មាន ការអនុវត្តសិទ្ធិមនុស្ស ការអនុវត្តច្បាប់ ការផ្តល់ថវិកាពីថ្នាក់ជាតិសម្រាប់ការប្រើប្រាស់នៅក្នុងពន្ធនាគារ ដើម្បីធានាក្នុងការអនុវត្តសិទ្ធិអ្នកជាប់ឃុំ ការអនុវត្តថវិកា ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិ នៅខេត្តសៀមរាប ព្រះវិហារ ឧត្តរមានជ័យ ព្រះសីហនុ និងខេត្តកោះកុង<br>+ អញ្ជើញចុះតាមដានការអនុវត្តច្បាប់ស្តីពីផ្លូវជាតិ និងបញ្ហាប្រឈម ព្រមទាំងការឈ្វេងយល់អំពីដំណើរការចែកចាយ និងទូទាត់ថ្លៃថាមពលអគ្គិសនីនៅតាមអនុស្ដានីយ៍នានា នៅខេត្តពោធិ៍សាត់ៗ | |

**៣- មុខងារតំណាង**

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
| --- | --- |
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា៖<br>+ អញ្ជើញនាំយកគ្រឿងឧបភោគ បរិភោគ ទេយ្យទាន ទេយ្យវត្ថុ ទៅចូលរួមក្នុងពិធីកាន់បិណ្ឌ និងប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសល ជូនដល់ដួងវិញ្ញាណក្ខន្ធសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម និងលោកជំទាវ ញ៉ែម សឿន ជាស៊ីម និងថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាទាំងអស់ដែលបានចែកឋានទៅកាន់លោកខាងមុខ ព្រមទាំងបុព្វការីជន និងញាតិកាទាំងប្រាំពីរសន្តានទៅតាមបណ្តាវត្តនានាក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តតាកែវ<br>+ អញ្ជើញចុះជួបសំណេះសំណាល និងសាកសួរសុខទុក្ខសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន ប្រធានប៉ុស្តិ៍រដ្ឋបាល និងប្រជាពលរដ្ឋនៅខេត្តក្រចេះ និងខេត្តកណ្តាល ព្រមទាំងប្រជាពលរដ្ឋដែលកំពុងទទួលរងផលប៉ះពាល់ និងរងគ្រោះដោយសារទឹកជំនន់ នៅខេត្តកំពង់ចាម<br>+ អញ្ជើញជាអធិបតីក្នុងពិធីបញ្ចុះសព និងដឹកនាំគណៈប្រតិភូ គោរពវិញ្ញាណក្ខន្ធសព ឯកឧត្តមនាយឧត្តមសេនីយ៍ ប៊ូ ថង អតីតប្រធានគណៈកម្មការទី២ ព្រឹទ្ធសភា និងគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម នួន សាមិន ទីប្រឹក្សាសម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា និងសព | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ជាគណៈអធិបតីក្នុងពិធីផ្លូវការនានា និងកិច្ចប្រជុំផ្សេងៗសរុបចំនួន២០៨លើក<br>- បានរៀបចំទិវាមនុស្សចាស់ក្នុងក្របខ័ណ្ឌអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានសហការចាត់ចែង និងរៀបចំពិធីបុណ្យសព ឯកឧត្តមនាយឧត្តមសេនីយ៍ ប៊ូ ថង អតីតប្រធានគណៈកម្មការទី២ ព្រឹទ្ធសភា នៅខេត្តរតនគិរី<br>- ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចូលរួមគាំទ្របរិច្ចាគថវិកាជូនមូលនិធិគន្ធបុប្ផាកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- បានផ្ញើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៥៥ច្បាប់ ស្មើនឹង១៩៨នាក់<br>- បានថតចម្លងឯកសារចំនួន៨៥៩ច្បាប់ អស់ក្រដាសចំនួន១,២៧៧សន្លឹក<br>- បានផ្តល់សេវារថយន្តសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្ត ក្រុងចំនួន១២៦លើក ស្មើនឹង ៦៦៥នាក់<br>- បានទទួលលិខិតចូលចំនួន២៣៨ច្បាប់ និងបញ្ជូនលិខិតចេញចំនួន២៦០ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក |

| | |
|---|---|
| ឯកឧត្តមឧត្តមសេនីយ៍ឯក ស៊ឹម តៃ នាយការិយាល័យចារកិច្ចនៃក្រសួងការពារជាតិ ព្រមទាំងគោរពវិញ្ញាណក្ខន្ធសពអតីតប្រធានាធិបតីនៃសាធារណរដ្ឋបារាំង នៅស្ថានទូតបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅរាជធានីភ្នំពេញ ខេត្តរតនគិរី និងខេត្តកំពង់ចាម<br>+ អញ្ជើញជាអធិបតីក្នុងអង្គវេទិកាភូមិភាគទី១ នៅរាជធានីភ្នំពេញ<br>+ អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីសាធារណរដ្ឋបារាំង ទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅខេត្តកណ្ដាល។<br>- ក្រុមសមាជិកសមាជិកាព្រឹទ្ធសភាប្រចាំភូមិភាគទី១ បានធ្វើវេទិកាចំនួន០១លើក ស្ដីពី ការអនុវត្តថវិកាថ្នាក់ក្រោមជាតិ (រាជធានី ខណ្ឌ សង្កាត់) ក្នុងការអភិវឌ្ឍមូលដ្ឋាន ដើម្បីផ្ដល់សេវាជូនប្រជាពលរដ្ឋប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព នៅរាជធានីភ្នំពេញ<br>- ព្រឹទ្ធសភាបានទទួលពាក្យបណ្ដឹងចំនួន០១ករណី ធ្វើកំណត់បង្ហាញពាក្យបណ្ដឹងចំនួន០១ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយចំនួន០៥ករណី និងឆ្លើយតបទៅម្ចាស់បណ្ដឹងចំនួន០៤ករណី កំពុងពិនិត្យសិក្សាចំនួន០២ករណី ព្រមទាំងទទួលឯកសារពាក្យបណ្ដឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធ បញ្ជូនមកគណៈកម្មការ ដើម្បីជូនជ្រាបចំនួន០៧ករណី | សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន៥៥លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់ និងទៅបំពេញបេសកកម្មនៅខេត្តរតនគិរី ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន០១លើក ស្មើនឹង០៥នាក់<br>- បានផ្ដល់អត្ថបទព័ត៌មាន និងរូបភាពស្ដីពីសកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីផ្សព្វផ្សាយតាមគេហទំព័រ និងបណ្ដាញសង្គមព្រឹទ្ធសភាចំនួន៣៣លើក<br>- បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន១៨២នាក់ អនុញ្ញាតឱ្យខ្ចីសៀវភៅចំនួន២៣ក្បាល និងសងវិញចំនួន២១ក្បាល<br>- បានផលិតទស្សនាវដ្ដីប្រចាំខែកញ្ញា ឆ្នាំ២០១៩ ចំនួន២,៥០០ក្បាល<br>- បានផលិតសៀវភៅស្ដីពី វឌ្ឍនភាពព្រឹទ្ធសភារយៈពេល២០ឆ្នាំ ចំនួន២០០ក្បាល<br>- បានថត និងផ្សព្វផ្សាយព័ត៌មានស្ដីពី សកម្មភាពការងាររបស់ព្រឹទ្ធសភាចំនួន២២លើក។ |

| | |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ទូទាំងប្រទេសចំនួន១១១លើក ដើម្បីជួបពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋក្នុងការរកវិធានការជួយសង្គ្រោះប្រជាពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្សេងៗសរុបចំនួន៨១លើក។ | |

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្តេចប្រមុខរដ្ឋស្តីទី បានអនុញ្ញាតឱ្យនាយករដ្ឋមន្ត្រីនៃប្រទេសម៉ាឡេស៊ី នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រមទាំងឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពតែងតាំងថ្មីនៃព្រះរាជាណាចក្រជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបជូនសារតាំង សវនាការ និងសម្តែងការគួរសម | - អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍សមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង (ASGPF) នៅប្រទេសបែលហ្ស៊ិក<br>- បានរៀបចំទីកន្លែងជូនថ្នាក់ដឹកនាំព្រឹទ្ធសភា សម្រាប់ជូនសារតាំង សវនាការ និងសម្តែងការគួរសម ជាមួយភ្ញៀវអន្តរជាតិចំនួន០៤លើក<br>- បានថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំ |

| | |
|---|---|
| - ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា បានអនុញ្ញាតឱ្យឯកឧត្តមអនុប្រធានសមាគមយោគយល់ជាអន្តរជាតិ និងជាអនុប្រធានគណៈកម្មាធិការកិច្ចការបរទេសនៃសភាក្រុមប្រឹក្សានយោបាយប្រជាជនចិន និងជាអតីតអនុរដ្ឋមន្ត្រីក្រសួងទំនាក់ទំនងអន្តរជាតិនៃគណបក្សកុម្មុយនីស្ត-ចិន ចូលជួបសម្តែងការគួរសម<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានជួបពិភាក្សាការងារ និងសម្តែងការគួរសម ជាមួយភ្ញៀវជនជាតិជប៉ុន និងនាយកគ្រប់គ្រងកម្មវិធីទូរទៅ Cambodia Digital TV Co.,LTD ខេត្តយូរណាន នៃសាធារណរដ្ឋប្រជាមានិតចិន ព្រមទាំងក្រុមការងាររៀបចំ Congres de AIME (Association International des Maries Francophone )<br>- សមាជិកព្រឹទ្ធសភា បានអញ្ជើញទៅចូលរួមសិក្ខាសាលាស្តីពី លំនៅដ្ឋានក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិច លើកទី៧ នៅព្រះរាជាណាចក្រ-ថៃឡង់ដ៍។ | ព្រឹទ្ធសភាជួបភ្ញៀវជាតិ និងអន្តរជាតិ មកបំពេញទស្សនកិច្ចនៅព្រឹទ្ធសភាចំនួន០២លើក<br>- បានថតចម្លងឯកសារចំនួន៦០ច្បាប់ អស់ក្រដាសចំនួន១,៤៧៧សន្លឹក<br>- បានរៀបចំសម្អាត តុបតែងលម្អសាល ផ្គត់ផ្គង់សម្ភារប្រើប្រាស់ និងបម្រើសេវាកេសជ្ជៈ ក្នុងកិច្ចប្រជុំចំនួន០៨លើក មានអ្នកចូលរួមចំនួន១២នាក់<br>- បានធ្វើកំណត់បង្ហាញ កំណត់ទូត របាយការណ៍លិខិតឆ្លើយតប បកប្រែឯកសារ និងឯកសារជំនួយស្មារតីពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ច សង្គម សភាប្រទេសជាដៃគូ និងលិខិតផ្សេងៗជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងគណៈ-ប្រតិភូនានារបស់ព្រឹទ្ធសភាចំនួន១៦លើក<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៥នាក់ ស្មើនឹង០៥ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា អញ្ជើញទៅបំពេញបេសកកម្មនៅក្នុង និងក្រៅប្រទេស ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន១៦លើក<br>- បានផ្តល់សេវារថយន្តសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្ត ក្រុងនានាចំនួន២៥លើក ស្មើនឹង ១១៤នាក់<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខ |

| | |
|---|---|
| | ផ្ទៃក្នុងចំនួន០៧លើក ស្មើនឹង២៥នាក់<br>- បានរៀបចំបែបបទជូនសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញទៅចូលរួមសន្និសីទ នៅសាធារណរដ្ឋសង្គមនិយមវៀតណាមចំនួន០១លើក<br>- បានរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញទៅបំពេញទស្សនកិច្ចសិក្សា និងចូលរួមមហាសន្និបាតសន្និសីទនៅសាធារណរដ្ឋបារាំង ប្រទេសបែលហ្ស៊ិក និងសាធារណរដ្ឋសង្គមនិយមវៀតណាមចំនួន០៣លើក។ |

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

| *របនាសម្ព័ន្ធនយោបាយ* | *របនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| | - បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣៦២ច្បាប់<br>- បានពិនិត្យវាយតម្លៃការអនុវត្តផែនការប្រតិបត្តិរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំត្រីមាសទី៣ ឆ្នាំ២០១៩<br>- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី សកម្មភាពការងារព្រឹទ្ធសភា និងអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភាប្រចាំខែកញ្ញា និងនព្វមាសឆ្នាំ២០១៩ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៥៤០ច្បាប់។<br>- ការងារគ្រប់គ្រងបុគ្គលិកៈ<br>+ បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៧៦១ច្បាប់<br>+ បានប្រជុំរៀបចំកម្មវិធីវគ្គបណ្តុះបណ្តាលបឋមសម្រាប់មន្ត្រីរាជការក្របខ័ណ្ឌថ្មីនៃអគ្គលេខា- |

| | |
|---|---|
| | ធិការដ្ឋានព្រឹទ្ធសភា<br>+ បានរៀបចំរចនាសម្ព័ន្ធ គោលការណ៍ និងគោលនយោបាយថ្មីៗ។<br>- **ការងារបណ្តុះបណ្តាលធនធានមនុស្ស៖**<br>+ បានបើកវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសចំនួន១១វគ្គ មានសិក្ខាកាមសរុបចំនួន១២១នាក់ សិក្ខាសាលាក្នុង និងក្រៅប្រទេសចំនួន០៣លើក មានសិក្ខាកាមសរុបចំនួន០៣នាក់។<br>- **ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖**<br>+ បានប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>+ បានប្រជុំបែងចែកថវិកាឆ្នាំ២០២០ របស់ព្រឹទ្ធសភាជូនក្រុមនយោបាយ និងរដ្ឋបាល<br>+ បានប្រជុំពិនិត្យ និងពិភាក្សាស្តីពី ការរៀបចំថវិកាកម្មវិធីសម្រាប់អនុវត្តឆ្នាំ២០២០ ជាមួយអង្គភាពថវិកា<br>+ បានប្រជុំផ្សព្វផ្សាយស្តីពី ការបញ្ជ្រាបការយល់ដឹងពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>+ បានរៀបចំតភ្ជាប់បណ្តាញប្រព័ន្ធ (FMIS)<br>+ បានរៀបចំរបាយការណ៍ចំណូល និងចំណាយថវិកា ៤មាសទី១ ឆ្នាំ២០១៩ របស់ព្រឹទ្ធសភា ជូនគណៈកម្មាធិការអចិន្ត្រៃយ៍<br>+ បានរៀបចំរបាយការណ៍ស្តីពី ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ ប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិ |

ប្រចាំខែ ព្រមទាំងធ្វើតារាងប្រាក់ឧបត្ថម្ភរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

+ បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់ក្នុងកម្មវិធីសិក្ខាសាលា កិច្ចប្រជុំនានាចំនួន០៦សំណើ បានផ្គត់ផ្គង់សម្ភារអនាម័យ សម្ភារការិយាល័យ និងភេសជ្ជៈចំនួន៤៥សំណើ សម្រាប់កិច្ចប្រជុំផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

+ បានរៀបចំសម្អាត តុបតែងសាលប្រជុំ ផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន០៩លើក មានអ្នកចូលរួមចំនួន៥៦៩នាក់

+ បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន១៨៩លើក

+ បានថតចម្លងឯកសារចំនួន៣,១០២ច្បាប់ បង់ក្រងធ្វើជាសៀវភៅចំនួន៩០ក្បាល អស់ក្រដាសចំនួន២៩,៣១៥សន្លឹក ព្រមទាំងបានជួសជុលសម្អាតម៉ាស៊ីនថតចម្លង និងម៉ាស៊ីនព្រីនធ័រចំនួន១៥លើក

+ បានផ្តល់សេវារថយន្តសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញចំនួន១២៥លើក ស្មើនឹង១៥៣នាក់ៗ

| | |
|---|---|
| | - ការកសាង អភិវឌ្ឍន៍ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ៖<br>+ រៀបចំស្នើសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤<br>+ កំពុងជួសជុលអគារនាយកដ្ឋានរដ្ឋបាល<br>+ បានស្តារប្រព័ន្ធលូនៅក្បែរអគារA និងអគារខាងក្រោយខុទ្ទកាល័យចាស់<br>+ បន្តជួសជុលបណ្តាញអគ្គិសនី បណ្តាញទឹក ម៉ាស៊ីនត្រជាក់ ទ្វារចេញ-ចូល នៅសាលប្រជុំពេញអង្គ អគារក្រហម អគារ DEF អគារជប៉ុន និងសាលពិសេសធំ<br>+ បានកែលម្អសួនច្បារ និងបានរៀបចំដាំដើមឈើថ្មីក្នុងបរិវេណព្រឹទ្ធសភាចំនួន០៤លើក ស្មើនឹង០៥ប្លង់<br>+ ជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម បិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យ ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៦៧គ្រឿង/លើក<br>+ បានសហការជាមួយក្រុមហ៊ុន Maintenances ត្រួតពិនិត្យជណ្តើរយន្តចំនួន០២លើក<br>+ សហការជាមួយក្រុមហ៊ុនកម្ចាត់សត្វកណ្តៀរ និងប្រចាំការម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ ព្រមទាំងបានត្រួតពិនិត្យការប្រើប្រាស់ទឹក ភ្លើង ក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាកចំនួន២៩លើក<br>+ បានរៀបចំបំពាក់ប្រព័ន្ធកាមេរ៉ាវីដេអូ សម្រាប់ផ្តិតយករូបភាពរាល់សកម្មភាពក្នុងកិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ នៅសាលបណ្ណាល័យ<br>+ បានបង្កើត Email, Telegram ជាមធ្យោបាយ |

| | |
|---|---|
| | សម្រាប់ទទួល និងបញ្ជូនឯកសារ ជូនសមាជិក សមាជិកាព្រឹទ្ធសភា<br>+ បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Connect Wifi និងដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និង Set up កម្មវិធីសរុបចំនួន៩៣គ្រឿង និងបាន Upload សេចក្តីជូនដំណឹង ព្រឹត្តិបត្រព័ត៌មានសុខភាព ទស្សនាវដ្តី និងរូបភាពសកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភា សរុបចំនួន១១៩ប្រធានបទ។<br>- **ការងារផ្សេងៗ៖**<br>+ បានតុបតែងលម្អ តាំងពិព័រណ៍រូបភាព និងចងទង់ជាតិក្នុងពិធីផ្សេងៗចំនួន០៨លើក<br>+ បានផលិតព័ត៌មានទាន់ហេតុការណ៍ និងផលិតខ្សែវីដេអូ សម្រាប់បង្ហោះលើ Alert News ចំនួន ១០៣ប្រធានបទ<br>+ បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៣៨លើក<br>+ បានទទួល និងរៀបចំសៀវភៅច្បាប់ និងឯកសារតាមជំនាញផ្សេងៗចំនួន១២១ក្បាល ព្រមទាំងបានចុះបញ្ជីសៀវភៅ បោះត្រា បិទប័ណ្ណខ្ចី និងសងសៀវភៅ អ៊ិតក្របសៀវភៅ បញ្ចូលសៀវភៅភាសាអង់គ្លេសក្នុងកម្មវិធី KOHA ចំនួន២៧៧ក្បាល<br>+ បានបញ្ចូលឯកសារ សៀវភៅច្បាប់ សៀវភៅបោះពុម្ពដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងជំនាញផ្សេងៗតាម E-Library & NAS ចំនួន ៦៣ក្បាល។ |

II-ទិសដៅការងារសម្រាប់ខែតុលា ឆ្នាំ២០១៩

**១- មុខងារនីតិកម្ម**

-ត្រៀមធ្វើរបាយការណ៍ស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៣ និងទី៤ នីតិកាលទី៤

-ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ដើម្បីពិនិត្យ និងឱ្យយោបល់លើ៖

១-សេចក្តីព្រាងច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់

២-សេចក្តីព្រាងច្បាប់ស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច

៣-សេចក្តីព្រាងច្បាប់ស្តីពី របបសន្តិសុខសង្គម

៤- កិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងអង្គការហាមឃាត់អាវុធគីមី ( OPCW) ស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អង្គការហាមឃាត់អាវុធគីមី (OPCW)

៥- សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី២ ស្តីពី ការកំណត់ច្រកទ្វារព្រំដែនកាត់នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពី កិច្ចសម្របសម្រួលការដឹកជញ្ជូនទំនិញឆ្លងកាត់

៦- សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី២ ស្តីពី ការកំណត់ច្រកទ្វារព្រំដែនកាត់នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពី ការចៀសវាងយកពន្ធត្រួតគ្នា និងការបង្ការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

៧-សេចក្តីព្រាងច្បាប់ស្តីពី សំណង់

៨- សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

៩-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី ការបង្កើតសម្ព័ន្ធភាពថាមពលពន្លឺព្រះអាទិត្យ។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-ត្រៀមសហការ និងសម្របសម្រួលការងារជូនគណៈកម្មការជំនាញ ជួបសវនាការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងៗ និងការចុះបេសកកម្មទៅខេត្តឧត្តរមានជ័យ។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំកម្មវិធីជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងចូលរួមក្នុងពិធីផ្លូវការនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា

-ត្រៀមសហការរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ជួបសវនាការ សម្ដែងការគួរសម និងជួបសំណេះសំណាលជាមួយឥស្សរជនជាន់ខ្ពស់ជាតិ និងអន្តរជាតិ

-ត្រៀមរៀបចំសិក្ខាសាលា និងពិធីសំណេះសំណាលផ្សេងៗ

-ត្រៀមរៀបចំវេទិកានៅខេត្តកំពង់ចាម ខេត្តកំពត ខេត្តមណ្ឌលគិរី និងខេត្តពោធិ៍សាត់

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ**

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអគ្គទូតនានា

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទៅបំពេញបេសកកម្មក្រៅប្រទេស

-ត្រៀមចូលរួមមហាសន្និបាត IPU និង ASGP នៅប្រទេសស៊ែប៊ី (ថ្ងៃទី១០-១៩ ខែតុលា ឆ្នាំ២០១៩)

-ត្រៀមចូលរួមប្រជុំស្ដីពី ការបង្កើតបណ្ដាញក្រុមសីលធម៌សមាជិកសភាប្រើភាសាបារាំងនៅប្រទេសបែលហ្ស៊ិក (ថ្ងៃទី៨-១២ ខែតុលា ឆ្នាំ២០១៩)

-ត្រៀមទៅបំពេញទស្សនកិច្ចសិក្សានៅសាធារណរដ្ឋបារាំង (ថ្ងៃទី២៩ ខែសីហា - ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៩)

-ត្រៀមចូលរួមជាមួយរដ្ឋសភា ដើម្បីរៀបចំ ASEP/ASEM ឆ្នាំ២០២០

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្ដាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការចាប់ផ្ដើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន គណៈកម្មការ និងក្រុមនានា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា កសាង Program និង Software ដើម្បីអនុវត្តតាមអង្គភាព និងការបណ្ដុះបណ្ដាលក្នុងនោះចូលរួមអនុវត្តកម្មវិធី Eបណ្ណាល័យ និង E បណ្ណសារ

-បន្តប្រជុំគណៈកម្មការគោលការណ៍ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តបម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍ពីប្រទេសផ្សេងៗទៀត

-ត្រៀមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) អភិវឌ្ឍធនធានមនុស្ស

ព័ត៌មាន និងទំនាក់ទំនងសាធារណៈ ការស្រាវជ្រាវ និងសហប្រតិបត្តិការអន្តរជាតិ

-ត្រៀមប្រជុំពិនិត្យ និងវាយតម្លៃវឌ្ឍនភាពសមិទ្ធកម្មប្រចាំត្រីមាសទី៣ និងផែនការសកម្មភាពប្រចាំត្រីមាសទី៤ ឆ្នាំ២០២០

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការជាក់ស្តែង

-ចាត់ចែងការរៀបចំប្រទីបសម្រាប់បុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក

-ត្រៀមរៀបចំថវិកា សម្ភារៈ និងគ្រឿងឧបភោគ បរិភោគ សម្រាប់ថ្នាក់ដឹកនាំព្រឹទ្ធសភាឧបត្ថម្ភកីឡាករអុំទូក

-ត្រៀមលក្ខណៈចូលរួមពិធីបុណ្យសំខាន់ៗនានារួមមាន៖ ពិធីគោរពព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ ទិវាកិច្ចព្រមព្រៀងទីក្រុងប៉ារីស ពិធីគ្រងរាជសម្បត្តិព្រះមហាក្សត្រ បុណ្យឯករាជ្យជាតិ បុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ទិវាសិទ្ធិមនុស្សអន្តរជាតិ និងពិធីបុណ្យជាតិផ្សេងៗទៀត

-ត្រៀមបោះពុម្ពជំណាច់ឆ្នាំ៖ ប័ណ្ណជូនពរ ទិនានុលេខន៍ ប្រតិទិន និងប័ណ្ណរថយន្ត

-ត្រៀមបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

-ត្រៀមការងារបុគ្គលិកឆ្នាំ២០១៩ និងផែនការឆ្នាំ២០២០

-ត្រៀមការងារបណ្តុះបណ្តាលឆ្នាំ២០១៩ និងផែនការឆ្នាំ២០២០

-ត្រៀមការងារលទ្ធកម្មឆ្នាំ២០១៩ និងផែនការឆ្នាំ២០២០

-ត្រៀមរៀបចំបែងចែកកញ្ចប់ថវិកាឆ្នាំ២០២០សម្រាប់រចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល

-ត្រៀមរបាយការណ៍ទូទាត់ថវិកាឆ្នាំ២០១៩

-ត្រៀមរបាយការណ៍បែងចែក និងប្រើប្រាស់ថវិកាឆ្នាំ២០២០

-បន្តសហការជាមួយក្រុមការងារ FMIS របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប្រើប្រាស់ប្រព័ន្ធFMIS

-ត្រៀមរៀបចំថវិកាតាមកម្មវិធីរួម និងតាមអង្គភាពថវិកាឆ្នាំ២០២០។

**III-សេចក្តីសន្និដ្ឋាន**

ក្នុងខែកញ្ញានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចូលរួមរៀបចំពិធីកាន់បិណ្ឌ បុណ្យភ្ជុំបិណ្ឌ និងពិធីផ្សេងៗទៀតជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បានយ៉ាងល្អប្រសើរ។ ចំពោះមុខងារតាមដានការអនុវត្តច្បាប់ បានបំពេញការងារយ៉ាងសកម្មក្នុងការចុះសិក្សាឈ្វេងយល់តាមវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការនានា។ ទន្ទឹមនឹងនេះ មុខងារតំណាង បានសហការសម្របសម្រួលដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ និងបានអមដំណើរសមាជិកព្រឹទ្ធសភាចុះតាមមូលដ្ឋាន ដើម្បីឈ្វេងយល់អំពីសុខទុក្ខ ដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានារបស់ប្រជាពលរដ្ឋ

នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្ត ក្រុងនានា។ ដោយឡែកលើមុខងារអភិវឌ្ឍន៍ស្ថាប័ន និងមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ ដោយរក្សាបាននូវភាពជាដៃគូជាមួយបណ្ដាប្រទេស បណ្ដាសភា និងដៃគូអភិវឌ្ឍន៍សំខាន់ៗជាច្រើនទៀត ដើម្បីបង្កើតឱកាសថ្មីសម្រាប់ព្រឹទ្ធសភាធ្វើដំណើរទៅមុខប្រកបដោយគុណភាព និងប្រសិទ្ធភាព។

ការផ្ដល់សេវាចាំបាច់ផ្សេងៗបម្រើជូនថ្នាក់ដឹកនាំ បានដំណើរការដោយរលូន និងគ្របដណ្ដប់លើច្រើនវិស័យ។ ៚

ថ្ងៃ ព្រហ ១១កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែតុលា ឆ្នាំ២០១៩

**អគ្គលេខាធិការ**

**អ៊ុំ សារិទ្ធ**